01034543

E320/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 31 / 10 / 2014
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

**សាធារណៈ / Public**

**ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤**

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ ÷** **សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤**

១. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្រោយពីទទួលការព្រមានពីអង្គជំនុំជម្រះរួចមក មេធាវីការពារក្តីទាំងពីរក្រុមបានចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ កាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ដែលនៅពេលនោះ មេធាវីការពារក្តីទាំងពីរក្រុមបានបង្ហាញមូលហេតុនានាដើម្បីគាំទ្រចំពោះទង្វើរបស់ពួកគេកាលពីពេលកន្លងទៅ និងបានបញ្ជាក់ថា ពួកគេមិនមានបំណងក្នុងការចូលរួមសវនាការលើអង្គសេចក្តី នៅក្នុងកាលៈទេសៈនាពេលបច្ចុប្បន្ននេះនោះទេ។ អង្គជំនុំជម្រះបានស្តាប់នូវសំណើសុំទាំងនេះ និងធ្វើការពិចារណាទៅលើសំណើនេះដូចខាងក្រោម។

២. ក្រុមមេធាវីការពារក្តីរបស់ នួន ជា លើកឡើងថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (“CPC”) តម្រូវឲ្យចៅក្រមដែលត្រូវបានប្តឹងជំទាស់ ផ្អាកការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីភ្លាម (ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៦៧)។ នៅក្នុងបរិបទនេះ អង្គជំនុំជម្រះសូមយោងទៅសេចក្តីសម្រេចមុនរបស់ខ្លួន (ឯកសារ E320 កថាខណ្ឌ ២) ដែលអង្គជំនុំជម្រះបានបញ្ជាក់អំពីលទ្ធភាពរបស់ចៅក្រមដែលត្រូវបានប្តឹងជំទាស់ក្នុងការបន្តការជំនុំជម្រះតទៅទៀត ក្នុងពេលកំពុងរង់ចាំសេចក្តីសម្រេចលើបណ្តឹងជំទាស់ ដោយអនុលោមតាមវិធាន ៣៤(៥) នៃវិធានផ្ទៃក្នុង។ ការយោងរបស់មេធាវីការពារក្តី នួន ជា ទៅលើផ្នែកមួយនៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងបរិបទនេះ គឺដោយមានការភ័ន្តច្រឡំ។ នៅក្នុង

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បណ្តឹងជំទាស់ផ្ទុយនឹងសេចក្តីសម្រេចរបស់ចៅក្រមនាពេលនោះ ក្រោយមានចែងនៅក្នុង មាត្រា ៥៥៦ ដែលបានចែងពីមូលហេតុជាក់លាក់ចំនួនប្រាំពីរ នៃការប្តឹងជំទាស់។ ផ្ទុយទៅវិញ វិធានផ្ទៃក្នុងនៃ អ.វ.ត.ក បានផ្តល់នូវមូលហេតុលើការប្តឹងជំទាស់ដែលមានលក្ខណៈទូលំទូលាយជាងនោះ[1]។ ផ្នែកបន្ទាប់ទៀតស្តីពីបណ្តឹងជំទាស់ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ខុសពីនីតិវិធីដែលអនុវត្តនៅក្នុង អ.វ.ត.ក ពាក់ព័ន្ធនឹងបណ្តឹងជំទាស់។ ឧទាហរណ៍ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៅពេលដែលបណ្តឹងជំទាស់ត្រូវបានបដិសេធចោល អ្នកប្តឹងជំទាស់អាចត្រូវទទួលពិន័យ និងទទួលខុសត្រូវលើការខូចខាតចំពោះចៅក្រមដែលត្រូវបានប្តឹងជំទាស់ (មាត្រា ៥៦១)។ គោលការណ៍នេះមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក ទេ។

៣. ក្រុមមេធាវីការពារក្តី ខៀវ សំផន លើកឡើងថា ជនជាប់ចោទមានសិទ្ធិចូលរួមយ៉ាងពេញលេញនៅក្នុងការការពារខ្លួនដោយផ្ទាល់ និងថា គាត់មិនអាចធ្វើការការពារខ្លួនឲ្យបានពេញលេញទេ នៅពេលដែលគាត់ត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ផង និងធ្វើការរៀបចំបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ផងក្នុងពេលតែមួយ [ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (សេចក្តីព្រាងប្រតិចារឹកជាភាសាបារាំង) ទំព័រ ៨, ១៣-១៧ (*សូមមើលផងដែរ* ឯកសារ E314/5/1)]។ អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីលើកឡើងថា ជនជាប់ចោទបានប្រឈមមុខនឹងជម្រើស រវាងការចំណាយពេលវេលាផ្ទាល់ខ្លួនដើម្បីធ្វើការរៀបចំបណ្តឹងសាទុក្ខរបស់គាត់ ឬការចូលរួមនៅក្នុងដំណើរការសវនាការ [ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (សេចក្តីព្រាងប្រតិចារឹកជាភាសាបារាំង) ទំព័រ ២៥]។ ដោយយោងទៅលើមូលហេតុនេះ ជនជាប់ចោទបានសម្រេចចំណាយពេលពេញលេញដើម្បីធ្វើការរៀបចំបណ្តឹងសាទុក្ខរបស់គាត់ និងបានណែនាំដល់មេធាវីការពារក្តីរបស់គាត់ឲ្យធ្វើតាមដូច្នេះដែរ [ប្រតិចារឹក ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៧៥-៧៧, ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (សេចក្តីព្រាងប្រតិចារឹកជាភាសាបារាំង) ទំព័រ ៧]។ ក្រុមមេធាវីការពារក្តី ខៀវ សំផន លើកឡើងថា ក្រោយពីមានការណែនាំពីជនជាប់ចោទរួចមក (ដែលក្រុមមេធាវីការពារក្តីយល់ស្របតាម៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (សេចក្តីព្រាងប្រតិចារឹកជាភាសាបារាំង) ទំព័រ ១៩) មេធាវីការពារក្តីនឹងមិនចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ នាពេលនេះទេ (ទំព័រ ២០) ដោយសារការចូលរួមនេះនឹងធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពរបស់ខ្លួន ដើម្បីបំពេញការងារឲ្យបានពេញលេញនៅលើ

---

[1] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធនិង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល នួន ជា, ណុន ចៅក្រមSilvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ឯកសារ E55/4 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ ,កថាខណ្ឌ ១០។

បណ្តឹងសាទុក្ខ (ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (សេចក្តីព្រាងប្រតិចារឹកជាភាសាបារាំង) ទំព័រ ១៨-១៩)។ ស្ថានភាពនេះត្រូវបានរំពឹងថា នឹងបន្តរហូតដល់ពេលដែលក្រុមមេធាវីការពារក្តី ខៀវ សំផន បានបញ្ចប់សារណាលើបណ្តឹងសាទុក្ខរបស់ខ្លួនសិន [*សូមមើល*ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (សេចក្តីព្រាងប្រតិចារឹកជាភាសាបារាំង) ទំព័រ ២២, ៣០, ៣៤-៣៥][2]។

៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការព្រួយបារម្ភជាចម្បងដែលបានបញ្ជាក់យ៉ាងច្បាស់ដោយក្រុមមេធាវីការពារក្តី ខៀវ សំផន នោះ គឺលទ្ធភាពរបស់កូនក្តីពួកគេក្នុងការរៀបចំបណ្តឹងសាទុក្ខ។ កិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់ប្រឆាំងនឹងជនជាប់ចោទ គឺកំពុងតែប្រព្រឹត្តទៅនៅក្នុងសវនាការ និងទៅលើបណ្តឹងសាទុក្ខ។ វាមិនមែនជាជម្រើសដែលត្រូវជ្រើសរើសរវាងកិច្ចដំណើរការនីតិវិធីទាំងពីរនេះនោះទេ ទោះបីជាក្នុងរយៈពេលមួយមានកំណត់ក្តី។ ដូចគ្នានេះដែរ ការលើកឡើងថា សិទ្ធិរបស់ជនជាប់ចោទដើម្បីចូលរួមឲ្យបានពេញលេញនៅក្នុងការការពារខ្លួន ត្រូវបានរំលោភ ដោយសារជនជាប់ចោទមិនអាចចំណាយពេលវេលាទាំងអស់របស់គាត់ ដើម្បីបំពេញការងារទៅលើបណ្តឹងសាទុក្ខនោះ គឺជាការលើកឡើងផ្ទុយទៅនឹងយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធ។ យុត្តិសាស្ត្រទាំងនោះបញ្ជាក់ថា ការចូលរួមនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ គឺជាបញ្ហាបច្ចេកទេសពាក់ព័ន្ធនឹងការកំណត់ទៅលើកំហុសសំខាន់ៗផ្នែកអង្គច្បាប់ ឬអង្គហេតុនៅក្នុងសាលក្រម ដែលទទួលស្គាល់ថាជាកិច្ចការទទួលខុសត្រូវជាចម្បងរបស់មេធាវីដែលត្រូវបានចាត់តាំង[3]។ ហេតុដូច្នេះ សំណើសុំការពន្យារពេលវេលាដើម្បីកំណត់កាលបរិច្ឆេទដាក់សារណាត្រូវបានបដិសេធ ទោះបីជាសាលក្រមដែលកំពុងត្រូវបានប្តឹងសាទុក្ខនេះ មិនទាន់មានជាភាសារបស់ជនជាប់ចោទក៏ដោយ។ បន្ថែមពីលើនេះទៀត ក្រុមមេធាវីការពារក្តី ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួនរួចហើយ។

---

[2] អាស្រ័យលើសេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំពន្យារពេលវេលា ដែលកាលបរិច្ឆេទសុំពន្យារពេលវេលានោះគឺ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ការពន្យារពេលចំនួន ១៧៤ ថ្ងៃ ត្រូវបានយោងទៅលើសំណើសុំ ដែលទាក់ទងនឹងការបញ្ចប់ការបកប្រែជាភាសាអង់គ្លេស។ ប៉ុន្តែ សហមេធាវីការពារក្តីរបស់ ខៀវ សំផន បានលើកឡើងថា ក្រុមមេធាវីការពារក្តីនឹងរួចរាល់ដើម្បីបន្តការចូលរួមក្នុងសំណុំរឿង ០០២/០២ នៅពាក់កណ្តាលខែ មករា (ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (សេចក្តីព្រាងប្រតិចារឹកជាភាសាបារាំង) ទំព័រ ៣១]

[3] ព្រះរាជអាជ្ញា ទល់នឹង ជនជាប់ចោទ Boskoski និង Tarculovski សំណុំរឿងលេខ IT-04-82-A សេចក្តីសម្រេចលើសំណើរបស់ Johan Tarculovski ស្នើសុំការពន្យារពេលវេលាដើម្បីដាក់សារណាលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២។ ព្រះរាជអាជ្ញា ទល់នឹង ជនជាប់ចោទ Popovic និងជនជាប់ចោទផ្សេងទៀត សំណុំរឿងលេខ IT-05-00-A សេចក្តីសម្រេចលើសំណើសុំពន្យារពេលវេលា និងចំនួនទំព័រលើសការកំណត់ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៤។

៥. អង្គជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទនៅក្នុងការចូលរួមនៅក្នុងការការពារខ្លួនចំពោះការប្ដឹងសាទុក្ខ ត្រូវបានគោរពតាមរយៈការចូលរួមយ៉ាងពេញលេញពីសំណាក់មេធាវីការពារក្ដីរបស់គាត់ដោយមានការគាំទ្រពីជនជាប់ចោទ។ អាស្រ័យហេតុនេះ ការពាក់ព័ន្ធរបស់ ខៀវ សំផន នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខ គឺមិនមានមូលដ្ឋានផ្លូវច្បាប់រឹងមាំសម្រាប់ឱ្យជនជាប់ចោទ ឬមេធាវីការពារក្ដីរបស់គាត់ មិនចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើសំណុំរឿង ០០២/០២ នេះទេ។

៦. ដើម្បីធ្វើឱ្យមានតុល្យភាពរវាងតម្រូវការចាំបាច់សម្រាប់ក្រុមមេធាវីការពារក្ដី ខៀវ សំផន និង ការធានាសិទ្ធិរបស់ភាគីនានាក្នុងការទទួលបាននូវការជំនុំជម្រះឱ្យបានឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូងបានត្រៀមលក្ខណៈក្នុងការបន្ថយចំនួនថ្ងៃធ្វើសវនាការមកត្រឹមពីរថ្ងៃក្នុងមួយសប្ដាហ៍នៅក្នុងអំឡុងខែ វិច្ឆិកា និងខែ ធ្នូ ឆ្នាំ ២០១៤។ អង្គជំនុំជម្រះកត់សម្គាល់ថា ចំនួនថ្ងៃសវនាការសរុបសម្រាប់ខែ វិច្ឆិកា គឺមានចំនួន ០៤ ថ្ងៃ និង សម្រាប់ខែ ធ្នូ មានចំនួន ០៦ ថ្ងៃ។

៧. បន្ទាប់ពីបានបដិសេធចោលសំណើចម្បងរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន រួចមក បញ្ហាតម្រូវឱ្យមានធនធានគ្រប់គ្រាន់សម្រាប់ក្រុមមេធាវីការពារក្ដី គឺជាបញ្ហាដែលជាប់ពាក់ព័ន្ធគ្នា។ បើទោះបីមេធាវីការពារក្ដីមិនបានលើកឡើងបញ្ហានេះដើម្បីធ្វើជាមូលហេតុតវ៉ានៅក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការក្ដី ក៏អង្គជំនុំយល់ឃើញថា ការពិភាក្សាខ្លះៗលើបញ្ហានេះ គឺជាការសមស្រប។ អង្គជំនុំជម្រះបានដឹងថា កន្លងមក ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំធនធានបន្ថែមពីការិយាល័យរដ្ឋបាល ហើយអង្គជំនុំជម្រះនឹងពិចារណាដោយយកចិត្តទុកដាក់លើសំណើនេះ និងសំណើសុំធនធានបន្ថែមសមស្របផ្សេងទៀត ដែលដាក់ដោយក្រុមមេធាវីការពារក្ដី ដើម្បីបង្កលក្ខណៈឱ្យពួកគេអាចចូលរួមបានដំណាលគ្នា ទាំងក្នុងកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខផង និងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្នចំពោះមុខអង្គជំនុំជម្រះនេះផង។

៨. ទាក់ទងនឹងបញ្ហាមិនមានឱកាសគ្រប់គ្រាន់ដើម្បីជួបជាមួយជនជាប់ចោទវិញ ទោះបីអង្គជំនុំជម្រះកត់សម្គាល់ថា ខៀវ សំផន ខ្លួនឯងបានបញ្ជាក់រួចហើយថា គាត់មានទំនាក់ទំនងស្ទើរតែរាល់ថ្ងៃជាមួយមេធាវីការពារក្ដីរបស់គាត់ក្ដី (សូមមើល ប្រតិចារិក ថ្ងៃទី ២៨ តុលា ២០១៤ (សេចក្ដីព្រាងប្រតិចារិកភាសាបារាំង) ទំព័រ ៧, ៣៥-៣៦, ៣៩) អង្គជំនុំជម្រះមានសម្មានចិត្តនឹងគាំទ្រដល់សំណើទាំងឡាយដែលសមស្រប ក្នុងការជួបប្រាស្រ័យទាក់ទងរវាងមេធាវី និងជនជាប់ចោទ ដែលអាចត្រូវបានស្នើឡើង។ ទោះបីជាយ៉ាងនេះក្ដី អង្គជំនុំជម្រះរំពឹងថា មេធាវីការពារក្ដីនឹងព្យាយាមរៀបចំជាមួយអានុរក្សមន្ទីរឃុំឃាំងដោយផ្ទាល់ជាមុនសិន។

៩. អង្គជំនុំជម្រះនៅតែរក្សាទុកសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យចាត់តាំងមេធាវី បម្រុង (amici curiae counsel) (ឯកសារ E321) ហើយអង្គជំនុំជម្រះមិនទាន់បង្ហាញជំហររបស់ខ្លួនទៅលើសំណើសុំនេះនៅឡើយទេ នៅដំណាក់កាលនេះ។

១០. អាស្រ័យហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ឱ្យភាគីទាំងអស់ត្រូវចូលរួមនៅក្នុងសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ដែលនឹងត្រូវចាប់ផ្ដើមធ្វើចាប់ពីថ្ងៃច័ន្ទទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ តទៅ។ អង្គជំនុំជម្រះនឹងផ្ដល់ដល់ភាគី ក្នុងពេលវេលាសមស្របនូវព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការប្រែប្រួលណាមួយ ដែលអាចកើតមានឡើងចំពោះដីកាកំណត់លំដាប់លំដោយក្នុងការកោះហៅសាក្សី ដែលអង្គជំនុំជម្រះបានចេញនាពេលកន្លងមក។

១១. ផ្អែកលើការប្រព្រឹត្ដិ និងសេចក្ដីថ្លែងការណ៍នានាដែលបានកើតមាននាពេលកន្លងមកនេះ (*សូមមើល* ឧ. សម្រាប់ នួន ជា ប្រតិចារិក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៧១, សម្រាប់ ខៀវ សំផន ប្រតិចារិក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (សេចក្ដីព្រាងប្រតិចារិកជាភាសាបារាំង) ទំព័រ ២១, ៣៤-៣៥) អង្គជំនុំជម្រះជូនដំណឹងដល់ក្រុមមេធាវីការពារក្ដី ខៀវ សំផន និង នួន ជា ឱ្យបានដឹងជាមុនថា អង្គជំនុំជម្រះនឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ប្រសិនបើក្រុមមេធាវីការពារក្ដីណាមួយ ខកខានមិនបានគោរពតាមដីកាបង្គាប់ឱ្យចូលរួមនៅក្នុងសវនាការខាងមុខនេះ។